**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ : ៥៣ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតទីភ្នាក់ងារកម្ពុជាប្រឆាំងដូប៉ា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៤ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងអនុសញ្ញាអន្តរជាតិប្រឆាំងនឹងការប្រើប្រាស់សារជាតុដូប៉ាក្នុងវិស័យកីឡា
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើត**ទីភ្នាក់ងារកម្ពុជាប្រឆាំងដូប៉ា** ដែលសរសេរជាអក្សរកាត់ថា **ទ.ក.ប.ដ.** និងជាភាសាអង់គ្លេសថា Cambodia Anti-Doping Agency សរសេរជាអក្សរកាត់ថា CADA ដើម្បីចូលរួមអនុវត្តអនុសញ្ញាអន្តរជាតិប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

## ជំពូកទី២
## តួនាទីនិងភារកិច្ចរបស់ ទ.ក.ប.ដ.

**មាត្រា២ .-**

**ទ.ក.ប.ដ.** មានតួនាទីជាសេនាធិការរបស់រាជរដ្ឋាភិបាលលើការអនុវត្តអនុសញ្ញាអន្តរជាតិប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព បទប្បញ្ញត្តិផ្សេងៗពាក់ព័ន្ធនឹងការប្រឆាំងដូប៉ាក្នុងវិស័យកីឡា
- ផ្សព្វផ្សាយបទប្បញ្ញត្តិដទៃទៀត និងអនុម័តលក្ខន្តិកៈប្រឆាំងដូប៉ាក្នុងវិស័យកីឡា
- ស្រាវជ្រាវនិងចងក្រងកម្មវិធីប្រឆាំងដូប៉ាក្នុងវិស័យកីឡា
- ស្រាវជ្រាវសារធាតុនិងវិធីសាស្ត្រដែលត្រូវបានហាមឃាត់
- ផ្សព្វផ្សាយបញ្ជីសារធាតុនិងវិធីសាស្ត្រដែលត្រូវបានហាមឃាត់
- ត្រួតពិនិត្យការអនុវត្តអនុសញ្ញាអន្តរជាតិប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា និងក្រមប្រឆាំងដូប៉ាពិភពលោក
- រៀបចំរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញាអន្តរជាតិប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា ជូនអង្គការយូណេស្កូនិងអង្គការអន្តរជាតិដែលពាក់ព័ន្ធ
- ត្រួតពិនិត្យការអនុវត្តលក្ខន្តិកៈប្រឆាំងដូប៉ារបស់សហព័ន្ធកីឡាជាតិ និងសហព័ន្ធកីឡាដទៃទៀត
- លើកទឹកចិត្តក្រសួង ស្ថាប័នពាក់ព័ន្ធ វិស័យឯកជន ដៃគូសហការ និងអង្គការមិនមែនរដ្ឋាភិបាលចូលរួមការប្រឆាំងដូប៉ាក្នុងវិស័យកីឡា
- ត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តលក្ខន្តិកៈប្រឆាំងដូប៉ារបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ចូលរួមប្រជុំពាក់ព័ន្ធនឹងការប្រឆាំងដូប៉ាក្នុងវិស័យកីឡាកម្រិតជាតិ តំបន់ និងអន្តរជាតិ។

## ជំពូកទី៣
## ការប្រព្រឹត្តទៅរបស់ ទ.ក.ប.ដ.

**មាត្រា៣ .-**

**ទ.ក.ប.ដ.** ត្រូវដឹកនាំដោយប្រធាន១(មួយ)រូប និងមានអនុប្រធានមួយចំនួនតាមការចាំបាច់ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ប្រធាន **ទ.ភ.ប.ជ.** ត្រូវតែងតាំងដោយអនុក្រឹត្យ។

អនុប្រធាន **ទ.ភ.ប.ជ.** ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៤ .-**

**ទ.ភ.ប.ជ.** មានមន្ត្រីបម្រើការងារជាមន្ត្រីរាជការក្នុងក្របខ័ណ្ឌមុខងារសាធារណៈនៃក្រសួងអប់រំ យុវជន និងកីឡា។ ក្នុងករណីចាំបាច់ **ទ.ភ.ប.ជ.** អាចមានអ្នកជំនាញការ និងអាចស្នើសុំមន្ត្រីជាប់កិច្ចសន្យា ដើម្បីជួយបំពេញការងាររបស់ខ្លួន ដោយមានការពិគ្រោះយោបល់ជាមុនជាមួយក្រសួងមុខងារសាធារណៈនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៥ .-**

**ទ.ភ.ប.ជ.** មានការិយាល័យចំណុះចំនួន២(ពីរ) គឺការិយាល័យរដ្ឋបាល ផែនការ អប់រំ និងផ្សព្វផ្សាយ និងការិយាល័យត្រួតពិនិត្យដូប៉ា។

**ទ.ភ.ប.ជ.** អាចមានការិយាល័យផ្សេងទៀតតាមការចាំបាច់ ដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះ **ទ.ភ.ប.ជ.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៦ .-**

**ទ.ភ.ប.ជ.** មានក្រុមប្រឹក្សាភិបាល ដើម្បីតម្រង់ទិស ផ្តល់យោបល់ និងជំរុញការអនុវត្តអនុសញ្ញាអន្តរជាតិប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា និងក្រមប្រឆាំងដូប៉ាពិភពលោក។

**មាត្រា៧ .-**

**ទ.ភ.ប.ជ.** មានគណៈកម្មការជំនាញចំនួន២(ពីរ) គឺគណៈកម្មការគ្រប់គ្រងលទ្ធផលដូប៉ានិងពិន័យ និងគណៈកម្មការលើកលែងការប្រើប្រាស់ថ្នាំព្យាបាល។

**មាត្រា៨ .-**

អង្គការលេខនៃរចនាសម្ព័ន្ធរបស់ **ទ.ភ.ប.ជ.** ជាឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

**មាត្រា៩ .-**

**ទ.ភ.ប.ជ.** មានរូបសញ្ញានិងត្រាដោយឡែករបស់ខ្លួន សម្រាប់ដំណើរការការងារ។

រូបសញ្ញារបស់ **ទ.ភ.ប.ជ.** ជាឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

គំរូត្រារបស់ **ទ.ភ.ប.ជ.** ជាឧបសម្ព័ន្ធទី៣នៃអនុក្រឹត្យនេះ។

## ជំពូកទី៤
## ក្រុមប្រឹក្សាភិបាល ទ.ភ.ប.ជ.

**មាត្រា១០ .-**

ក្រុមប្រឹក្សាភិបាល **ទ.ភ.ប.ជ.** មានភារកិច្ចដូចខាងក្រោម៖

- អនុម័តលើគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព បទប្បញ្ញត្តិផ្សេងៗពាក់ព័ន្ធនឹងការប្រឆាំងដូប៉ាក្នុងវិស័យកីឡា

- តម្រង់ទិស ផ្តល់យោបល់ និងជំរុញការអនុវត្តអនុសញ្ញាអន្តរជាតិប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា និងក្រមប្រឆាំងដូប៉ាពិភពលោក
- ពិនិត្យ តាមដាន និងផ្តល់យោបល់លើរបាយការណ៍អនុវត្តអនុសញ្ញាអន្តរជាតិប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា
- តាមដាននិងតម្រង់ទិសលើការងាររបស់ **ឧ.ក.ប.ដ.** ក្នុងការជំរុញក្រសួង ស្ថាប័នពាក់ព័ន្ធ វិស័យឯកជន ដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាលចូលរួមការប្រឆាំងដូប៉ាក្នុងវិស័យកីឡា។

**មាត្រា១១ .-**

ក្រុមប្រឹក្សាភិបាល **ឧ.ក.ប.ដ.** មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | ប្រធាន |
| - រដ្ឋលេខាធិការនៃក្រសួងមហាផ្ទៃ ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការនៃក្រសួងអប់រំ យុវជន និងកីឡា ១រូប | អនុប្រធានប្រចាំការ |
| - រដ្ឋលេខាធិការនៃក្រសួងសុខាភិបាល ១រូប | សមាជិក |
| - រដ្ឋលេខាធិការនៃក្រសួងយុត្តិធម៌ ១រូប | សមាជិក។ |

សមាសភាពជាក់ស្តែងនៃក្រុមប្រឹក្សាភិបាល **ឧ.ក.ប.ដ.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា១២ .-**

ក្រុមប្រឹក្សាភិបាល **ឧ.ក.ប.ដ.** ត្រូវប្រជុំយ៉ាងតិច២(ពីរ)ដងក្នុងមួយឆ្នាំ តាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីចាំបាច់ ប្រធានក្រុមប្រឹក្សាភិបាល **ឧ.ក.ប.ដ.** អាចកោះប្រជុំវិសាមញ្ញ។ នៅពេលដែលប្រធានក្រុមប្រឹក្សាភិបាល **ឧ.ក.ប.ដ.** អវត្តមានឬមានករណីចាំបាច់ ប្រធានអាចផ្ទេរសិទ្ធិជូនអនុប្រធានណាម្នាក់ដើម្បីដឹកនាំការប្រជុំ។ ក្រុមប្រឹក្សាភិបាល **ឧ.ក.ប.ដ.** ត្រូវមានដំណើរការការងារស្របតាមបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។

**មាត្រា១៣ .-**

ក្រុមប្រឹក្សាភិបាល **ឧ.ក.ប.ដ.** មានសិទ្ធិប្រើរូបសញ្ញានិងត្រារបស់ក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៥
## គណៈកម្មការជំនាញនៃ ឧ.ក.ប.ដ.

### ផ្នែកទី១
### គណៈកម្មការគ្រប់គ្រងលទ្ធផលដូប៉ានិងពិន័យ

**មាត្រា១៤ .-**

គណៈកម្មការគ្រប់គ្រងលទ្ធផលដូប៉ានិងពិន័យ ត្រូវបំពេញតួនាទីនិងភារកិច្ចស្របតាមស្តង់ដាអន្តរជាតិស្តីពីការគ្រប់គ្រងលទ្ធផលដូប៉ា និងក្រមប្រឆាំងដូប៉ាពិភពលោក មានជាអាទិ៍៖

- ដោះស្រាយវិវាទបឋម
- ដោះស្រាយលើបណ្តឹងតវ៉ា។

**មាត្រា១៥ .-**

គណៈកម្មការគ្រប់គ្រងលទ្ធផលដូប៉ានិងពិន័យ មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - មេធាវី ១រូប | ប្រធាន |
| - វេជ្ជបណ្ឌិត ១រូប | អនុប្រធាន |
| - អតីតមន្ត្រីកីឡា ១រូប | អនុប្រធាន |
| - អតីតអត្តពលិក ១រូប | សមាជិក |
| - មេធាវី ២រូប | សមាជិក |
| - វេជ្ជបណ្ឌិត ២រូប | សមាជិក |
| - អ្នកជំនាញបច្ចេកទេសពាក់ព័ន្ធ ២រូប | សមាជិក។ |

សមាសភាពជាក់ស្តែងនៃគណៈកម្មការគ្រប់គ្រងលទ្ធផលដូប៉ានិងពិន័យ ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាភិបាល **ទ.ភ.ប.ដ.**។

គណៈកម្មការគ្រប់គ្រងលទ្ធផលដូប៉ានិងពិន័យ អាចមានសមាសភាពបន្ថែមជាអនុប្រធានឬសមាជិកផ្សេងទៀតតាមការចាំបាច់។ សមាសភាពបន្ថែមនេះត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាភិបាល **ទ.ភ.ប.ដ.**។

សមាសភាពនៃគណៈកម្មការនេះ ត្រូវមានលក្ខណសម្បត្តិដែលកំណត់ដោយប្រធានក្រុមប្រឹក្សាភិបាល **ទ.ភ.ប.ដ.** ស្របតាមស្តង់ដាអន្តរជាតិស្តីពីការគ្រប់គ្រងលទ្ធផលដូប៉ា និងក្រុមប្រឆាំងដូប៉ាពិភពលោក។

## ផ្នែកទី២
## គណៈកម្មការលើកលែងការប្រើប្រាស់ថ្នាំព្យាបាល

**មាត្រា១៦ .-**

គណៈកម្មការលើកលែងការប្រើប្រាស់ថ្នាំព្យាបាល ត្រូវបំពេញតួនាទីនិងភារកិច្ចស្របតាមស្តង់ដាអន្តរជាតិស្តីពីការលើកលែងការប្រើប្រាស់ថ្នាំព្យាបាល និងក្រុមប្រឆាំងដូប៉ាពិភពលោក មានជាអាទិ៍៖

- ពិនិត្យបញ្ជីសារធាតុនិងវិធីសាស្ត្រដែលត្រូវបានហាមឃាត់ក្នុងវិស័យកីឡា
- ពិនិត្យ តាមដាន និងផ្តល់ការលើកលែងប្រើប្រាស់ថ្នាំព្យាបាល
- ពិនិត្យនិងវាយតម្លៃប្រភេទជំងឺ និងថ្នាំដែលអត្តពលិកស្នើសុំប្រើប្រាស់សម្រាប់ព្យាបាល
- សម្រេចលើការស្នើសុំប្រើប្រាស់ថ្នាំព្យាបាលរបស់អត្តពលិក
- រៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តអនុសញ្ញាអន្តរជាតិប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា ពាក់ព័ន្ធនឹងការប្រើប្រាស់ថ្នាំនិងវិធីសាស្ត្រដែលត្រូវបានហាមឃាត់ ជូន **ទ.ភ.ប.ដ.**។

**មាត្រា១៧ .-**

គណៈកម្មការលើកលែងការប្រើប្រាស់ថ្នាំព្យាបាល មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - តំណាងក្រសួងសុខាភិបាល ១រូប | ប្រធាន |
| - វេជ្ជបណ្ឌិតឯកទេស ១រូប | អនុប្រធាន |
| - វេជ្ជបណ្ឌិត ៥រូប | សមាជិក |
| - អ្នកជំនាញបច្ចេកទេសពាក់ព័ន្ធ ៣រូប | សមាជិក។ |

សមាសភាពជាក់ស្តែងនៃគណៈកម្មការលើកលែងការប្រើប្រាស់ថ្នាំព្យាបាល ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាភិបាល **ទ.ភ.ប.ជ.**។

គណៈកម្មការលើកលែងការប្រើប្រាស់ថ្នាំព្យាបាល អាចមានសមាសភាពបន្ថែមជាអនុប្រធានឬសមាជិកផ្សេងទៀតតាមការចាំបាច់។ សមាសភាពបន្ថែមនេះត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាភិបាល **ទ.ភ.ប.ជ.**។

សមាសភាពនៃគណៈកម្មការនេះ ត្រូវមានលក្ខណសម្បត្តិដែលកំណត់ដោយប្រធានក្រុមប្រឹក្សាភិបាល **ទ.ភ.ប.ជ.** ស្របតាមស្តង់ដាអន្តរជាតិស្តីពីការលើកលែងការប្រើប្រាស់ថ្នាំព្យាបាល និងក្រុមប្រឆាំងដូប៉ាពិភពលោក។

## ជំពូកទី៦
## ប្រភពធនធានរបស់ ទ.ភ.ប.ជ.

**មាត្រា១៨ .-**

**ទ.ភ.ប.ជ.** មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិជាកញ្ចប់ថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា។

**ទ.ភ.ប.ជ.** មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់ប្រភពធនធានស្របច្បាប់ផ្សេងៗតាមការកំណត់របស់ច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមានសម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៧
## អន្តរប្បញ្ញត្តិ

**មាត្រា១៩ .-**

មន្ត្រីរាជការដែលបម្រើការងារនៅលេខាធិការដ្ឋានគណៈកម្មាធិការប្រឆាំងដូប៉ានៃកម្ពុជា ត្រូវផ្ទេរមកបំពេញតួនាទីភារកិច្ចនៅទីភ្នាក់ងារកម្ពុជាប្រឆាំងដូប៉ា។

លិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលពាក់ព័ន្ធនឹងការតែងតាំងមន្ត្រីរាជការចំណុះលេខាធិការដ្ឋានគណៈកម្មាធិការប្រឆាំងដូប៉ានៃកម្ពុជា ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀតរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**មាត្រា២០ .-**

អនុក្រឹត្យលេខ២៦០ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការប្រឆាំងដូប៉ានៃកម្ពុជា អនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានគណៈកម្មាធិការប្រឆាំងដូប៉ានៃកម្ពុជា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២១ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៦ កើត ខែ ផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ